# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** — **ក្រសួងយុត្តិធម៌**

លេខ ១១៩៧ សហវ-កយ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១០

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់អត្រាសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអ និងបំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតលេខ ១៤០០ សជណ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការសម្រេចកំណត់កម្រៃសេវារដ្ឋបាល និងការផ្តល់ប្រាក់ឧបត្ថម្ភជូនក្រសួងយុត្តិធម៌ លើការងារប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស
- បានឃើញប្រកាសលេខ ១៤០៥ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងកិច្ចដំណើរការគណនីនៃរជ្ជទេយ្យចំណូល
- បានឃើញសារាចរណែនាំលេខ ០១៣ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរជ្ជទេយ្យចំណូល
- បានឃើញប្រកាសលេខ ១៤៤៨ សហវ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- តាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ន

## សម្រេច

**ប្រការ ១** : ត្រូវបានអនុញ្ញាតឱ្យក្រសួងយុត្តិធម៌ ប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោសដែលជាប្រភេទព្រឹត្តិបត្រលេខ ៣ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

**ប្រការ ២** : សេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ត្រូវបានបែងចែកជាសេវាធម្មតា និងសេវាឆាប់រហ័ស។ សេវាធម្មតា គឺការផ្តល់ព្រឹត្តិបត្រថ្កោលទោសក្នុងរយៈពេលមិនលើសពី ២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។ សេវាឆាប់រហ័ស គឺការផ្តល់ព្រឹត្តិបត្រថ្កោលទោសក្នុងរយៈពេល ១២(ដប់ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។ ការផ្តល់សេវាឆាប់រហ័សនេះ ធ្វើឡើងចំពោះតែករណីចាំបាច់បន្ទាន់ ដែលសាមីជនត្រូវបង្ហាញទឡ្ហីករណ៍បញ្ជាក់អំពីភាពចាំបាច់បន្ទាន់នោះ ទៅតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងយុត្តិធម៌។

**ប្រការ ៣** : កម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ត្រូវបានកំណត់ដូចតារាងខាងក្រោម ៖

| បរិយាយ | កម្រៃសេវារដ្ឋបាល | |
|---|---|---|
| | សេវាធម្មតា | សេវាឆាប់រហ័ស |
| ១- ចំពោះជនជាតិខ្មែរ | ១០.០០០រៀល | ៤០.០០០រៀល |
| ២- ចំពោះជនជាតិបរទេស | ២៥០.០០០រៀល | ៥០០.០០០រៀល |

**ប្រការ ៤** : កម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ដែលបានកំណត់ក្នុងប្រការ ៣ ខាងលើនេះ បានគិតរួមបញ្ចូលទាំងតម្លៃនៃទម្រង់ឯកសារនានាសម្រាប់ការសរសេរបំពេញ ដើម្បីស្នើសុំព្រឹត្តិបត្រថ្កោលទោស។ លើកលែងតែថ្លៃពន្ធតែមប្រិ៍សារពើពន្ធ ដែលជាបន្ទុករបស់សាមីជន ដែលតម្រូវឱ្យបិទសន្លឹកតែមប្រិ៍សារពើពន្ធមានតម្លៃ ១.០០០រៀល នៅលើពាក្យស្នើសុំ និងបិទសន្លឹកតែមប្រិ៍សារពើពន្ធមានតម្លៃ ១.២០០រៀល នៅលើព្រឹត្តិបត្រថ្កោលទោស។

**ប្រការ ៥** : ក្រសួងយុត្តិធម៌ ត្រូវបិទផ្សាយជាសាធារណៈអំពីតារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីដែលត្រូវបំពេញ សម្រាប់ការស្នើសុំព្រឹត្តិបត្រថ្កោលទោស។

**ប្រការ ៦** : ការប្រមូលចំណូល ការកត់ត្រាតាមដាន ការបង់ប្រាក់ចំណូលចូលថវិកាជាតិ និងការទទួលខុសត្រូវប្រាក់កាសស្តីពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ជាភារកិច្ចរបស់រដ្ឋទេយ្យករចំណូលនៃក្រសួងយុត្តិធម៌។ រដ្ឋទេយ្យករចំណូល ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ជាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងចុះហត្ថលេខា រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី០៧ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៧** : រដ្ឋទេយ្យករចំណូល ត្រូវបង់ប្រាក់ចំណូលទាំងស្រុងចូលរតនាគារជាតិ និងធ្វើសលាកប័ត្របង់ចំណូលចូលថវិកាជាតិ ព្រមទាំងធ្វើការកត់ត្រាតាមដានចំណូលនៅក្នុងជំពូក គណនី និងអនុគណនី នៃមាតិកាថវិកាដែលបានកំណត់។

**ប្រការ ៨** : អនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភជូនក្រសួងយុត្តិធម៌ចំនួន ២០%(ម្ភៃភាគរយ) នៃប្រាក់ចំណូលដែលបានបង់ចូលថវិកាជាតិ សម្រាប់ជារង្វាន់លើកទឹកចិត្តផ្តល់ជូនមន្ត្រីរាជការដែលបំពេញការងារគ្រប់គ្រង និងមន្ត្រីដែលអនុវត្តការងារផ្ទាល់។ ការដកប្រាក់ឧបត្ថម្ភនេះ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយអនុវត្តនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ ៩** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១០** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ-វង្សវឌ្ឍនា

***ចម្លងជូន :***

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី*
- *អាជ្ញាធរសវនកម្មជាតិ*
- *គ្រប់ក្រសួង-ស្ថាប័ន*
- *គ្រប់សាលាខេត្ត និងសាលារាជធានីភ្នំពេញ*

  *«ដើម្បីជូនជ្រាប»*
- *ដូចប្រការ ១០ «ដើម្បីអនុវត្ត»*
- *ឯកសារ-កាលប្បវត្តិ*